CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៨ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# អាជីវកម្មលក់រាយខ្នាតតូចត្រូវបានអនុញ្ញាតឱ្យបើកជាថ្មីជាមួយនឹងការរឹតបន្តឹងផ្នែកសុខភាពនៅថ្ងៃទី ៨ ខែឧសភា

*ផ្លូវលំនិងទីលានវាយកូនហ្គោលក៏ត្រូវបើកឡើងវិញដោយមានការដាក់កម្រិតខ្លះ*

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា – ចាប់ពីថ្ងៃសុក្រទី ៨ ខែឧសភាឆ្នាំ ២០២០ ទីក្រុងឡុងប៊ិចនឹងអនុញ្ញាតឱ្យអាជីវកម្មលក់រាយខ្នាតតូចបើកសម្រាប់ការមកយកតាមដងផ្លូវឬដឹកជញ្ជូនដល់គេហដ្ឋានតែប៉ុណ្ណោះដោយមានប្រតិបត្តិការដែលបានកែលម្អឱ្យមានអនាម័យនិងរក្សាចំងាយរាងកាយពីគ្នា។ ការនេះបានអនុវត្តមួយថ្ងៃបន្ទាប់ពីទីក្រុងធ្វើការប្រកាសបើកជាថ្មីហើយដើម្បីតម្រឹមជាមួយនឹងទិសដៅបើកឡើងវិញដែលបានកំណត់ដោយលោកអភិបាលរដ្ឋ Newsom។

អភិបាលក្រុងលោក Robert Garcia មានប្រសាសន៍ថា "ការសម្រេចចិត្តក្នុងការបើកសេដ្ឋកិច្ចយើងឡើងវិញជាបណ្តើរៗគឺផ្អែកលើគោលការណ៍ណែនាំរបស់រដ្ឋ ស្ថានភាពសុខភាព និងទិន្នន័យផ្សេងៗ។ ខ្ញុំសង្ឃឹមថាជាមួយនឹងការគាំទ្រនិងសហប្រតិបត្តិការពីសហគមន៍យើងនឹងបន្តមានសុខភាពល្អនិងរក្សាចម្ងាយរាងកាយពីគ្នាទៅវិញទៅមក។"

លើសពីនេះទៀតផ្លូវលំនិងចំណតរថយន្តដែលជាប់នឹងផ្លូវលំ  ទីលានវាយកូនហ្គោល ហើយបន្ទប់តាំងលក់រថយន្តអាចបើកឡើងវិញបានដោយអាស្រ័យលើថាតើកន្លែងទាំងនេះប្រកាន់ខ្ជាប់ឬអត់នូវអនុសាសន៍និងពិធីសារសុវត្ថិភាពរបស់ទីក្រុង។

**ហាងលក់រាយដែលមិនចាំបាច់៖**

អាជីវកម្មលក់រាយដែលមិនចាំបាច់ដែលត្រូវបានអនុញ្ញាតឱ្យបើកឡើងវិញតាមការណែនាំរបស់លោកអភិបាលរដ្ឋ Newsom រួមមានដោយមិនកំណត់ចំពោះ៖

- ហាងលក់សៀវភៅ
- ហាងលក់គ្រឿងអលង្ការ
- ហាងលក់ប្រដាប់ក្មេងលេង
- ហាងលក់សម្លៀកបំពាក់
- ហាងលក់ស្បែកជើង
- ហាងលក់ផ្ទះនិងគ្រឿងសង្ហារិម
- ហាងលក់សម្ភារៈកីឡា
- ហាងលក់វត្ថុបុរាណ
- ហាងលក់តន្ត្រី
- ហាងលក់ផ្កា

ហាង ដែលមិនចាំបាច់ត្រូវតែប្រកាន់ខ្ជាប់នូវពិធីការខាងក្រោមដើម្បីបើកឡើងវិញបាន៖

- អនុញ្ញាតឱ្យមានការមកយកតាមដងផ្លូវឬដឹកជញ្ជូនដល់គេហដ្ឋានតែប៉ុណ្ណោះ។
- អនុវត្តពិធីសាររក្សាចម្ងាយរាងកាយពីគ្នាសម្រាប់ហាងលក់រាយមុនពេលដែលបើកឡើងវិញ។
- ហាមអតិថិជនមិនឱ្យចូលក្នុងហាង។
- ធានាថាការដែលអតិថិជនមកយករបស់តាមដងផ្លូវនឹងមិនប៉ះពាល់ឬរាំងចិញ្ចើមផ្លូវនិងតំបន់ជុំវិញដែលជាផ្លូវធ្វើដំណើររបស់ជនពិការ។
- ផ្តល់អាទិភាពដល់សុវត្ថិភាពបុគ្គលិកនិងសុវត្ថិភាពអតិថិជនរួមមាន៖
    - ផ្តល់របាំងមុខនិងស្រោមដៃដល់បុគ្គលិកនិងបង្ហាញពីរបៀបប្រើប្រាស់។ របាំងមុខនិងស្រោមដៃគឺតម្រូវឱ្យមានក្នុងកំឡុងពេលមកយកតាមដងផ្លូវនិងដឹកជញ្ជូន។

    - តម្រូវឱ្យនិងអនុញ្ញាតឱ្យបុគ្គលិកមានពេលវេលាគ្រប់គ្រាន់សម្រាប់ការលាងដៃយ៉ាងហោចណាស់រៀងរាល់ ៣០ នាទីម្តងឬតាមការចាំបាច់ប្រសិនបើមានស្រោមដៃ។
- តម្រូវឱ្យអតិថិជនពាក់របាំងមុខនៅពេលមកយករបស់។
- លើកទឹកចិត្តអតិថិជនអោយបង់លុយតាមទូរស័ព្ទឬតាមអ៊ិនធរណេតមុនពេលមកយករបស់។
- ផ្តល់សន្តិសុខឬបុគ្គលិកគ្រប់គ្រាន់ដើម្បីអនុវត្តការគ្រប់គ្រងហ្វូងមនុស្សបើចាំបាច់និងការផ្តល់ជំនួយភ្លាមៗដើម្បីមិនឱ្យមានការចាំបាច់តម្រង់ជួរ។

**ហាងលក់រថយន្ត៖**
- អាចបើកបន្ទប់តាំងបង្ហាញជាសាធារណៈ។
- តម្រូវឱ្យអនុវត្តពិធីសាររក្សាចម្ងាយរាងកាយពីគ្នាមុនពេលបើក។

ម្ចាស់អាជីវកម្មឬនិយោជិកអាចទូរស័ព្ទមកលេខ 562.570.4BIZ (4249) សម្រាប់ព័ត៌មានបន្ថែម។

**ផ្លូវលំ៖**
បុគ្គលដែលទៅដើរលេងនៅផ្លូវលំនៃឡុងប៊ិចត្រូវតែប្រកាន់ខ្ជាប់នូវចំណុចដូចខាងក្រោម៖
- ស្ថិតនៅចម្ងាយយ៉ាងតិចប្រាំមួយហ្វីតគ្រប់ពេលពីអ្នកដទៃដែលមិនមែនជាសមាជិកគ្រួសាររបស់លោកអ្នក។ ពិធីសារនេះអាចធ្វើឱ្យផ្លូវលំខ្លះប្រើបានល្អជាងផ្លូវផ្សេងទៀត។
- ចៀសវាងកន្លែងដែលមានមនុស្សច្រើន។
- របាំងមុខគឺតម្រូវឱ្យពាក់នៅពេលដើរជិតអ្នកដទៃប៉ុន្តែមិនបានតម្រូវនៅពេលកំពុងធ្វើការហាត់ប្រាណដែលរក្សាចំងាយរាងកាយពីអ្នកដទៃទេ។
- ផ្តល់នូវការឃ្លាតឆ្ងាយពីរាងកាយគ្រប់គ្រាន់នៅពេលដើរក្បែរអ្នកដទៃ។ ដើរចេញពីផ្លូវដើម្បីអនុញ្ញាតឱ្យអ្នកដទៃឆ្លងកាត់តាមតម្រូវការដែលអាចធ្វើទៅបានដោយសុវត្ថិភាព។
- នៅផ្ទះប្រសិនបើលោកអ្នកឈឺ។
- កុំប្រមូលផ្តុំគ្នាជាក្រុមឬនៅកន្លែងណាមួយក្នុងរយៈពេលយូរលើកលែងតែត្រូវការពេលវេលាខ្លីដើម្បីសម្រាក។
- កុំចែកអាហារឬទឹកនៅពេលដើរលើផ្លូវលំ។

**ទីលានវាយកូនហ្គោល៖**

ទីលានវាយកូនហ្គោលនៅឡុងប៊ិចអាចនឹងបើកហើយត្រូវប្រកាន់ខ្ជាប់នូវចំណុចដូចខាងក្រោម៖
- តម្រូវឱ្យអនុវត្តពិធីសាររក្សាចម្ងាយរាងកាយពីគ្នាសម្រាប់ទីលានវាយកូនគោលមុនពេលបើក។
- កន្លែងក្លឹបនឹងនៅតែបិទ។
- ហាងលក់ផលិតផលសម្រាប់អ្នកជំនាញវាយកូនហ្គោលអាចនឹងបើកសម្រាប់ការមកយករបស់តាមចិញ្ចើមផ្លូវ។
- ស្តង់ដែលលក់អាហារសម្រន់និងភោជនីយដ្ឋានដែលមានទីតាំងនៅទីលានវាយកូនហ្គោលអាចបើកសម្រាប់ការមកយកចេញតែប៉ុណ្ណោះ។
- មានការរំពឹងទុកថាទីលានវាយកូនហ្គោលក្រុងឡុងប៊ិចនឹងបើកដំណើរការជាថ្មីនៅថ្ងៃសៅរ៍ទី ៩ ខែឧសភាដើម្បីជានាពិធីសារសុវត្ថិភាពត្រឹមត្រូវនិងប្រតិបត្តិការអាជីវកម្មដែលបានកែប្រែរួចរាល់។ ទីលានវាយកូនហ្គោលក្រុងឡុងប៊ិចរួមមាន៖ Recreation Park Heartwell Park Skylinks និង El Dorado Park។

សូមយោងលើបទបញ្ជាសុខភាពពេញលេញសម្រាប់ព័ត៌មានលំអិតនិងព័ត៌មានបន្ថែម។

នៅថ្ងៃច័ន្ទទី ១១ ខែឧសភាឱកាសកំសាន្តបន្ថែមនឹងបើកជាសាធារណៈ។ ព័ត៌មានបន្ថែមនឹងត្រូវផ្តល់ជូននៅថ្ងៃក្រោយ។

រាល់ការកែប្រែដែលមានស្រាប់និងនាពេលអនាគតចំពោះបទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ" របស់មន្ត្រីសុខាភិបាលនៃទីក្រុងដែលពីមុនបានកំណត់អស់សុពលភាពថ្ងៃទី ១៥ ខែឧសភានឹងនៅតែមានប្រសិទ្ធិភាពរហូតដល់មានការជូនដំណឹងឬការធ្វើវិសោធនកម្មបន្ថែម។ ទីក្រុងឡុងប៊ិចនឹងបន្តធ្វើការកែប្រែដល់បទបញ្ជាតាមតម្រូវការដើម្បីការពារដល់សុខភាពសាធារណៈ។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាម អំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #